# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## នាយកក្រុមហ៊ុន ថេនថេក អ៊ីនដាសស្ទ្រៀល ខូ អិលធីឌី
## កិច្ចព្រមព្រៀង

រវាង

តំណាងរោងចក្រ ភាគី "ក" ជាមួយ ភាគី "ខ" តំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន

ឆ្នាំពីរពាន់ម្ភៃ(2020) ខែ សីហា ថ្ងៃទី ៣ វេលាម៉ោង ១០ និង ៣០នាទីថ្ងៃត្រង់នៅការិយាល័យរោងចក្រ ថេនថេក អ៊ីនដាសស្ទ្រៀល ខូ អិលធីឌី រវាង តំណាងរោងចក្រ ភាគី "ក" ជាមួយ ភាគី "ខ" តំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន ។ ក្រោយពីបានប្រជុំពិភាក្សា ភាគីទាំងពីរបានយល់ព្រមព្រៀងគ្នាដូចខាងក្រោមៈ

១-ភាគីទាំងពីរបានយល់ព្រមព្យួរការងាររយៈពេល ១ខែ ចំពោះកម្មករ និយោជិតចំនួន ៣៥ នាក់ មានផ្នែកដេរ ផ្នែកពិនិត្យគុណភាព ផ្នែកតុកាត់ ផ្នែកជាងម៉ាស៊ីន ផ្នែកអនាម័យ និងផ្នែកសាប់ ដោយគិតចាប់ពី ថ្ងៃទី ៧ ខែ សីហា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី ៧ ខែកញ្ញាឆ្នាំ២០២០ ដោយសាតែអ្នកបញ្ជាទិញផ្អាកការបញ្ជាទិញ ព្រោះប្រទេសទាំងនោះរងផលប៉ះពាល់ពីជម្ងឺរាលកផ្លូវដង្ហើមយ៉ាងធ្ងន់ធ្ងរពី ខូវីដ១៩ (COVID-19) ។

២-ភាគី "ខ" យល់ព្រមទទួលប្រាក់ ឧបត្ថម្ភ ៣០ ដុល្លាអាមេរិក ពី ភាគី "ក" និង ៤០ ដុល្លាអាមេរិក ដែលជាប្រាក់ឧបត្ថម្ភពិសេសរបស់រាជរដ្ឋាភិបាល ស្របទៅតាម សេចក្តីណែនាំរបស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជិវៈ លេខៈ០៤៥/២០ ក.ប/ស.ណ.ន.ខ.ល ស្តីពីការព្យួរកិច្ចសន្យាការងារ និងការផ្អាកបង់ភាគទាន ប ស ស សម្រាប់រោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលរងផលប៉ះពាល់ពីជម្ងឺរាលកផ្លូវដង្ហើមយ៉ាងធ្ងន់ធ្ងរពី ខូវីដ១៩ (COVID-19) ដូច្នេះជាសរុបកម្មករ និយោជិតម្នាក់ៗទទួលបាន ៧០ ដុល្លាអាមេរិក ក្នុង១ខែ សម្រាប់រយៈពេលព្យួរការងារនេះ។

៣-ភាគី "ក" និងបើក ៣០ ដុល្លាអាមេរិក នេះជូន ភាគី "ខ" នៅថ្ងៃទី ១០ខែ សីហា ឆ្នាំ២០២០នៃខែបន្ទាប់(តែមួយលើកប៉ុណ្ណោះ)។

៤-ភាគី "ខ" ត្រូវត្រលប់ចូលធ្វើការវិញនៅថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ២០២០ ក្នុងករណីបងប្អូន កម្មករមិនបានចូលធ្វើការតាមកាលកំណត់នោះទេ រោងចក្រនិងអនុវត្តន៍តាមបទបញ្ជាផ្ទៃក្នុង និងច្បាប់ស្តីពីការងារ។

កិច្ចព្រមព្រៀងនេះ ចាប់អនុវត្តន៍និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ១៤ កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤

ត្រូវនឹងថ្ងៃទី ៣ ខែសីហា ឆ្នាំ២០២០

ស្នាមមេដៃតំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន

១-ឈ្មោះ ប៉ាត់ សូណាត តួនាទី សហជីពមូលដ្ឋាន ស្នាមមេ.........................

២-ឈ្មោះ ស៊ីម សុខឃាង តួនាទី ប្រធានផ្នែកដេរ ស្នាមមេ.........................

នាយកឬតំណាងក្រុមហ៊ុន

ក្លូង ឡេងពន្លៃ

តួនាទី : រដ្ឋបាល

៣-ឈ្មោះ យ៉ត ស្រីនាត តួនាទី ប្រធានក្រុម ស្នាមមេ......................

៤-ឈ្មោះ គង់ ចេត តួនាទី ប្រធានក្រុម ស្នាមមេ......................

៥-ឈ្មោះ ជឹម ណោង តួនាទី ប្រធានក្រុម ស្នាមមេ......................

៦-ឈ្មោះ អុន សុភ័ស តួនាទី ប្រធានក្រុម ស្នាមមេ......................

៧-ឈ្មោះ មុយ សុខា តួនាទី ប្រធានក្រុម ស្នាមមេ......................

៨-ឈ្មោះ នឹម នាងណារិន តួនាទី ប្រតិភូបុគ្គលិក ស្នាមមេ......................

៩-ឈ្មោះ ប្រាក់ បុប្ផា តួនាទី ប្រធានក្រុម ស្នាមមេ......................

១០-ឈ្មោះ អ៊ុំ សុវណ្ណ តួនាទី ប្រធានក្រុម ស្នាមមេ......................

១១-ឈ្មោះ ព្រហ្ម ចិន តួនាទី ប្រធានក្រុម ស្នាមមេ......................